**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
## រវាង
## ក្រុមហ៊ុន ផាយឡឹត នីត ស្ព័ត វែរ (ខេមបូឌា) ខូអិលធីឌី
## និង
## តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ
## ក្រុមហ៊ុន ផាយឡឹត នីត ស្ព័ត វែរ (ខេមបូឌា) ខូអិលធីឌី
## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ១៣.០០ នាទីរសៀល នៅក្នុងក្រុមហ៊ុន ផាយឡឹត នីត ស្ព័ត វែរ (ខេមបូឌា)ខូអិលធីឌី មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករ និងសហជីពមូលដ្ឋានប្រចាំក្រុមហ៊ុន។

នៅក្នុងអង្គប្រជុំនេះ នាយិកាក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្វះសម្ភារវត្ថុធាតុដើម លុបចោលការបញ្ជាទិញពីភ្ញៀវ (Buyer) និង គ្មានការបញ្ជាទិញបន្តពីអ្នកបញ្ជាទិញ សម្រាប់សង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងអស់ ចំនួន ៤៨១ នាក់ (ស្រី ២៨៨ នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ៤៨១ នាក់ (ស្រី ២៨៨ នាក់) ដែលមានរយៈពេលចំនួន ១ ខែ គឺចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួលចំនួន ៥០% នៃប្រាក់ខែគោលក្នុង១ខែ ព្រមទាំងទទួលបាននូវអត្ថប្រយោជន៍ផ្សេងទៀតដូចជា ប្រាក់ធ្វើដំណើរនិងស្នាក់នៅ ១៥ ដុល្លារ ប្រាក់រង្វាន់ធ្វើការទៀងទាត់ ១២ ដុល្លារ និងប្រាក់តួនាទី រួមទាំងបូកបញ្ចូលថ្ងៃបុណ្យចំនួន៣ថ្ងៃទៀត។ ហើយប្រាក់ឈ្នួលនេះ នឹងបើកនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣។

អង្គប្រជុំបានចប់វេលាម៉ោង ១៥.០០ នាទីរសៀល នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និទ្ធស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

ថ្ងៃពុធ ១៤រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣

**តំណាងកម្មករ និង តំណាងសហជីព** | **នាយិកាក្រុមហ៊ុន**

ខាត់ ម៉ុចហួត មាស ស៊ីវ៉ា មិន សុផានិត ស៊ិន មករា

លោកស្រី ឌិវ៉ាត់អ:សេម គ្រិសវ៉ាន់

ស៊ុម គៀត ទូន សុខឿន ផៃ ស៊ីណែត ផែង បូរី រាប សុបូទុំ